ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៣៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់និងការបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារទេសភាព«ភ្នំក្រាំងដីមាស» ស្ថិតក្នុងភូមិសាស្ត្រស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២៣/០០៧ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើក្រមបរិស្ថាននិងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦១ អនក្រ.បក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩ ស្តីពីការបង្កើតតំបន់ការពារទេសភាព «ភ្នំក្រាំងដីមាស»
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១.-**

ត្រូវបានបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារទេសភាព«ភ្នំក្រាំងដីមាស» ជាពីរតំបន់ ស្ថិតក្នុងភូមិសាស្ត្រស្រុកលាប្អៀរ ខេត្តកំពង់ឆ្នាំង ដូចមានផែនទី និងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធ ដូចខាងក្រោម៖

១. តំបន់ប្រើប្រាស់ដោយចីរភាព មានផ្ទៃដីសរុបទំហំ ២០៣ (ពីររយបី) ហិកតា ស្ថិតក្នុងភូមិសាស្ត្រស្រុកលាប្អៀរ ខេត្តកំពង់ឆ្នាំង និងអនុប្បយោគប្តូរចំណាត់ថ្នាក់ពីទ្រព្យសម្បត្តិសាធារណៈរដ្ឋទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ សម្រាប់ប្រគល់ជូនក្រសួងការពារជាតិ ដើម្បីប្រើប្រាស់ជាទីតាំងដាក់រ៉ាដាល្បាតគ្រប់គ្រងដែនអាកាសចម្ងាយ៤០០គីឡូម៉ែត្រ និងជូនគណៈកម្មការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត បន្តនីតិវិធីចុះបញ្ជីជូនក្រសួងការពារជាតិ។

២. តំបន់សហគមន៍ មានផ្ទៃដីសរុបទំហំ ៨៥ (ប៉ែតសិបប្រាំ) ហិកតា ស្ថិតក្នុងភូមិសាស្ត្រស្រុកលាប្អៀរ ខេត្តកំពង់ឆ្នាំង សម្រាប់ប្រគល់ជូនជូនគណៈកម្មការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ដើម្បីរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវន្តបម្រើឱ្យរដ្ឋបាលឃុំក្រាំងដីមាស ដែលទើបបង្កើតថ្មី និងដោះស្រាយផលប៉ះពាល់នានា។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ច័ន្ទ ៨ រោច ខែ ទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ២០២៣ ✓

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**សម្តេចពិជ័យសេនា ទៀ បាញ់**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ផែនទីទីតាំងចំណុចនិយាមការឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ......អនក្រ.បក ចុះថ្ងៃ......ខែ......ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧ ចុះថ្ងៃទី......ខែ......ឆ្នាំ២០២៣




តារាងនិយាមការ
តំបន់ប្រើប្រាស់ដោយចីរភាពមានផ្ទៃដីទំហំ ២០៣ហិកតា

| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 460944 | 1355571 | 24 | 459616 | 1354593 |
| 2 | 460900 | 1355522 | 25 | 459506 | 1354539 |
| 3 | 460841 | 1355349 | 26 | 459295 | 1354491 |
| 4 | 460814 | 1355308 | 27 | 459168 | 1354530 |
| 5 | 460716 | 1355100 | 28 | 459113 | 1354664 |
| 6 | 460682 | 1355115 | 29 | 459112 | 1354919 |
| 7 | 460626 | 1355008 | 30 | 459103 | 1355215 |
| 8 | 460565 | 1355025 | 31 | 459177 | 1355388 |
| 9 | 460487 | 1354855 | 32 | 459315 | 1355512 |
| 10 | 460467 | 1354840 | 33 | 459464 | 1355694 |
| 11 | 460454 | 1354858 | 34 | 459569 | 1355758 |
| 12 | 460419 | 1354815 | 35 | 459691 | 1355936 |
| 13 | 460424 | 1354808 | 36 | 459851 | 1356001 |
| 14 | 460289 | 1354700 | 37 | 459958 | 1356127 |
| 15 | 460280 | 1354717 | 38 | 460017 | 1356167 |
| 16 | 460245 | 1354704 | 39 | 460367 | 1356023 |
| 17 | 460264 | 1354665 | 40 | 460523 | 1355950 |
| 18 | 460209 | 1354608 | 41 | 460630 | 1355911 |
| 19 | 460145 | 1354605 | 42 | 460669 | 1355856 |
| 20 | 460028 | 1354575 | 43 | 460712 | 1355749 |
| 21 | 459908 | 1354572 | 44 | 460811 | 1355686 |
| 22 | 459777 | 1354561 | 45 | 460892 | 1355674 |
| 23 | 459729 | 1354596 | 46 | 460935 | 1355655 |

តារាងនិយាមការ តំបន់សហគមន៍
មានផ្ទៃដីសរុប៨៥ ហិកតា

| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 460944 | 1355571 | 43 | 460083 | 1354531 |
| 2 | 461082 | 1355708 | 44 | 460119 | 1354584 |
| 3 | 461133 | 1355761 | 45 | 460028 | 1354575 |
| 4 | 461086 | 1355977 | 46 | 459303 | 1354572 |
| 5 | 461148 | 1355992 | 47 | 459777 | 1354561 |
| 6 | 461115 | 1356141 | 48 | 459729 | 1354596 |
| 7 | 461091 | 1356137 | 49 | 459616 | 1354593 |
| 8 | 461058 | 1356277 | 50 | 459506 | 1354539 |
| 9 | 460764 | 1356359 | 51 | 459295 | 1354491 |
| 10 | 460772 | 1356221 | 52 | 459163 | 1354530 |
| 11 | 460737 | 1356199 | 53 | 459113 | 1354664 |
| 12 | 460699 | 1356082 | 54 | 459112 | 1354919 |
| 13 | 460610 | 1356111 | 55 | 459103 | 1355215 |
| 14 | 460551 | 1356165 | 56 | 459177 | 1355388 |
| 15 | 460473 | 1356187 | 57 | 459315 | 1355512 |
| 16 | 460379 | 1356191 | 58 | 459464 | 1355694 |
| 17 | 460385 | 1356217 | 59 | 459569 | 1355758 |
| 18 | 460270 | 1356236 | 60 | 459691 | 1355936 |
| 19 | 460269 | 1356219 | 61 | 459851 | 1356001 |
| 20 | 460189 | 1356233 | 62 | 459958 | 1356127 |
| 21 | 460184 | 1356172 | 63 | 460017 | 1356167 |
| 22 | 460128 | 1356188 | 64 | 460367 | 1356023 |
| 23 | 460124 | 1356169 | 65 | 460523 | 1355950 |
| 24 | 460068 | 1356197 | 66 | 460630 | 1355911 |
| 25 | 460073 | 1356230 | 67 | 460669 | 1355856 |
| 26 | 459926 | 1356302 | 68 | 460712 | 1355749 |
| 27 | 459919 | 1356262 | 69 | 460311 | 1355686 |
| 28 | 459805 | 1356272 | 70 | 460892 | 1355674 |
| 29 | 459352 | 1355644 | 71 | 460935 | 1355665 |
| 30 | 459147 | 1355633 | 72 | 460716 | 1355100 |
| 31 | 459124 | 1355637 | 73 | 460682 | 1355115 |
| 32 | 459055 | 1355569 | 74 | 460626 | 1355008 |
| 33 | 458941 | 1355246 | 75 | 460659 | 1354999 |
| 34 | 458963 | 1355052 | 76 | 460457 | 1354840 |
| 35 | 458959 | 1354728 | 77 | 460454 | 1354858 |
| 36 | 459008 | 1354640 | 78 | 460419 | 1354815 |
| 37 | 459077 | 1354467 | 79 | 460424 | 1354808 |
| 38 | 459418 | 1354294 | 80 | 460289 | 1354700 |
| 39 | 459497 | 1354313 | 81 | 460280 | 1354717 |
| 40 | 459545 | 1354378 | 82 | 460245 | 1354704 |
| 41 | 459703 | 1354445 | 83 | 460264 | 1354665 |
| 42 | 459865 | 1354530 | | | |

តារាងនិយាមការផ្លូវ

| ID | X | Y |
|---|---|---|
| 1 | 460771.660 | 1354894.076 |
| 2 | 460723.798 | 1354909.047 |
| 3 | 460699.817 | 1354914.103 |
| 4 | 460684.722 | 1354914.146 |
| 5 | 460671.703 | 1354910.243 |
| 6 | 460653.788 | 1354904.98 |
| 7 | 460640.693 | 1354894.698 |
| 8 | 460620.812 | 1354855.738 |
| 9 | 460603.112 | 1354857.744 |
| 10 | 460586.232 | 1354852.817 |
| 11 | 460579.456 | 1354846.176 |
| 12 | 460506.137 | 1354845.897 |
| 13 | 460497.865 | 1354850.682 |
| 14 | 460494.444 | 1354862.784 |
| 15 | 460498.538 | 1354875.409 |
| 16 | 460521.292 | 1354892.472 |
| 17 | 460529.767 | 1354945.176 |